# សេចក្តីថ្លែងការណ៍ព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

## សាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤

ខ្ញុំជិតនឹងបញ្ចប់ដំណើរបេសកកម្មស្វែងរកការពិតអំពីបញ្ហាសិទ្ធិមនុស្សលើកទី១១ របស់ខ្ញុំ មកកាន់ព្រះរាជាណាចក្រកម្ពុជាហើយ ដែលនេះជាបេសកកម្មលើកទីពីរហើយ ចាប់តាំងពីមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលបានប្រព្រឹត្តទៅក្នុងខែកក្កដា ឆ្នាំ២០១៣ កន្លងទៅនេះ។ អ្វីដែលខ្ញុំស្នើឲ្យមានការបញ្ជាក់នោះ គឺទៅលើការរកឃើញ និងការគិតពីដំបូងរបស់ខ្ញុំ អំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសនេះ ចាប់តាំងពីបេសកកម្មចុងក្រោយរបស់ខ្ញុំ។ ការសន្និដ្ឋាន និងអនុសាសន៍ចុងក្រោយរបស់ខ្ញុំ នឹងបញ្ចូលនៅក្នុងរបាយការណ៍ដែលខ្ញុំនឹងបង្ហាញជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅក្នុងខែកញ្ញា ឆ្នាំនេះ។

ក្នុងពេលបំពេញបេសកកម្មនេះ ខ្ញុំបានជួបជាមួយ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីជាន់ខ្ពស់នៃតុលាការ អភិបាល និងអភិបាលរងខេត្តព្រះសីហនុ។ ដូចគ្នានឹងបេសកកម្មកន្លងមករបស់ខ្ញុំដែរ ខ្ញុំបានជួបពិភាក្សាផងដែរ ជាមួយអ្នកពាក់ព័ន្ធជាច្រើនទៀតនៅកម្ពុជា រួមទាំង ប្រជាពលរដ្ឋសាមញ្ញ ក្រុមយុវជន និងនិស្សិត អង្គការសង្គមស៊ីវិល មេដឹកនាំគណបក្សប្រឆាំង ព្រមទាំងសមាជិកសហគមន៍អន្តរជាតិ រួមទាំងដៃគូអភិវឌ្ឍន៍ និងក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា។ ខ្ញុំបានទទួលជួបផងដែរ ជាមួយប្រតិភូជាច្រើនក្រុម ដែលបានមកដាក់ញត្តិរបស់ពួកគាត់ដល់រូបខ្ញុំ។

ក្នុងដំណើរបេសកកម្មលើកនេះ ខ្ញុំអាចជួបប្រាស្រ័យទាក់ទងជាមួយអង្គការសិទ្ធិមនុស្សជាច្រើន ដែលធ្វើការងារក្នុងវិស័យផ្សេងៗ និងវាស់ស្ទង់អំពីស្ថានភាពសិទ្ធិមនុស្សទូទៅ រាប់ទាំងសិទ្ធិស្ត្រី សិទ្ធិជនពិការ សិទ្ធិស្រីស្រលាញ់ស្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (LGBTI)។ ខ្ញុំក៏អាចធ្វើដំណើរនៅ

ខាងក្រៅរាជធានីភ្នំពេញ និងមើលឲ្យឃើញផ្ទាល់ភ្នែកខ្ញុំ ពីស្ថានភាពពិតជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីសម្បទានដី និងការបណ្តេញចេញ នៅខេត្តកោះកុង និងខេត្តព្រះសីហនុ។

ជាបឋម ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការវិជ្ជមាន និងប្រកបដោយន័យស្ថាបនាដល់រូបខ្ញុំ នៅក្នុងដំណើរបេសកកម្មនេះ។ កិច្ចសន្ទនាដែលខ្ញុំមានជាមួយគូសន្ទនាពីខាងរដ្ឋាភិបាល គឺមានលក្ខណៈស្មោះត្រង់ ស្និទ្ធស្នាល និងទទួលបានព័ត៌មានច្រើន។

តាមការវាយតម្លៃជារួមរបស់ខ្ញុំ អំពីការវិវត្តលើស្ថានភាពសិទ្ធិមនុស្ស ខ្ញុំកត់សំគាល់ឃើញថា ដំណើរវិវឌ្ឍក្នុងវិស័យមួយចំនួន ជាទូទៅ ស្ថិតក្នុងទិសដៅវិជ្ជមានមួយ ហើយខ្ញុំនៅតែជឿជាក់ថា មានហេតុផលសុទិដ្ឋិនិយមសម្រាប់ការអភិវឌ្ឍប្រទេសជាតិរយៈពេលវែង។ កិច្ចសន្ទនា ដើម្បីដោះស្រាយភាពជាប់គាំងនយោបាយរវាងរាជរដ្ឋាភិបាល និងគណបក្សប្រឆាំង ទំនងជាកំពុងតែកើតមាន ចំពោះការបង្កើតបរិយាកាសមួយអំណោយផលដល់ការទទួលយកអសនៈក្នុងរដ្ឋសភា ដោយសមាជិកគណៈបក្សប្រឆាំង។ ញត្តិដ៏ច្រើនសន្ធឹកសន្ធាប់ ដែលខ្ញុំទទួលនៅក្នុងបេសកកម្មនីមួយៗ រាប់ទាំងបេសកកម្មលើកនេះផង បញ្ជាក់ថា មានការយល់ដឹងកាន់តែខ្លាំងឡើងក្នុងចំណោមប្រជាពលរដ្ឋអំពីសិទ្ធិមនុស្សរបស់ពួកគេ។ ពិតណាស់ លិទ្ធិប្រជាធិបតេយ្យ សំដៅដល់កិច្ចសន្ទនាគ្នាការពិភាក្សាដេញដោល និងការសម្របសម្រួលឲ្យមានការប្រកួតប្រជែងផលប្រយោជន៍ សម្រាប់បុព្វហេតុប្រទេសជាតិកាន់តែខ្លាំងឡើង។ ខ្ញុំសូមស្វាគមន៍ការដោះលែង បើទោះបីជាស្ថិតក្នុងលក្ខខណ្ឌព្យួរទោសក៏ដោយ ដល់ក្រុមប្រជាពលរដ្ឋចំនួន២៥ នាក់ ដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួនទាក់ទងនឹងព្រឹត្តការណ៍កាលពីខែវិច្ឆិកា ឆ្នាំ២០១៣ និងកាលពីខែមករា ឆ្នាំ២០១៤។ ទោះបីជាស្ថានភាពទូទៅ ទំនងជាមានស្ថិរភាពក្តី ក៏លំហសម្រាប់សេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងការបញ្ចេញមតិ ហាក់មានការរួមតូច បន្ទាប់ពីកើតមានឧប្បត្តិហេតុហិង្សាដ៏អកុសលបំផុតក្នុងសប្តាហ៍ទីមួយ ក្នុងខែមករា ឆ្នាំ២០១៤។ នៅពេលទៅមើលទីលានប្រជាធិបតេយ្យ ដែលជានិមិត្តរូបនៃលទ្ធិប្រជាធិបតេយ្យ ខ្ញុំបានឃើញផ្ទាល់ភ្នែកខ្ញុំ និងមានការសោកស្តាយជាខ្លាំងដោយឃើញថាទីនោះត្រូវបានហ៊ុំព័ទ្ធដោយបន្លារលួស រារាំងប្រជាពលរដ្ឋមិនឲ្យចូលទៅកាន់ទីនោះ ដើម្បីអនុវត្តសេរីភាពរបស់ពួកគេក្នុងការបញ្ចេញមតិ និងការជួបប្រជុំ។ វាបង្ហាញនូវចំណាប់អារម្មណ៍ថា មានការប៉ុនប៉ងដាក់លទ្ធិប្រជាធិបតេយ្យក្នុងទ្រុងមួយនៅប្រទេសកម្ពុជា! ខ្ញុំសង្ឃឹមថាស្ថានភាពនេះនឹងត្រូវបានដោះស្រាយ ហើយថាសិទ្ធិសេរីភាពក្នុងការជួបប្រជុំដែលធានាការពារដោយរដ្ឋធម្មនុញ្ញ រាប់ទាំងនៅទីលានប្រជាធិបតេយ្យផងនោះ នឹងត្រូវបានធ្វើឲ្យមានដូចស្ថានភាពដើមវិញ សម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

## កំណែទម្រង់ប្រព័ន្ធតុលាការ

របាយការណ៍សំខាន់លើកទីមួយ ដែលខ្ញុំបានដាក់ជូនអង្គការសហប្រជាជាតិ បន្ទាប់ពីការចូលកាន់តំណែងរបស់ខ្ញុំជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសនេះ បានផ្តោតសំខាន់លើកំណែទម្រង់ប្រព័ន្ធតុលាការ។ ការអនុម័តច្បាប់សំខាន់ៗចំនួនបី ស្តីពីប្រព័ន្ធតុលាការ គឺជាស្នូលនៃអនុសាសន៍របស់ខ្ញុំ។ អាស្រ័យហេតុនេះ ខ្ញុំស្វាគមន៍ជាគោលការណ៍នូវការអនុម័តច្បាប់សំខាន់ៗទាំងបីនេះ ដោយស្ថាប័នសភាទាំងពីរ។ ច្បាប់ទាំងនេះ មានបញ្ញត្តិមួយចំនួនដែលបានតាក់តែងឡើង សំដៅពង្រឹងយន្តការស្តីពីការប្រព្រឹត្តទៅនៃប្រព័ន្ធតុលាការ មានជាអាទិ៍ ការគ្រប់គ្រងសំណុំរឿង។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមានកង្វល់អំពីបញ្ញត្តិមួយចំនួនក្នុងច្បាប់ទាំងនេះ ដែលជាឧបសគ្គដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងដល់គោលការណ៍បែងចែកអំណាច។ ឧទាហរណ៍ មានបទបញ្ញត្តិមួយ ដែលមានវត្តមានរឹងមាំ និងមានឥទ្ធិពលរបស់អង្គនីតិប្រតិបត្តិនៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នមួយ ត្រូវបានប្រគល់អំណាចត្រួតពិនិត្យ និងគ្រប់គ្រងទូទៅលើប្រព័ន្ធតុលាការ។ ខ្ញុំមានកង្វល់ផងដែរ ចំពោះបទបញ្ញត្តិមួយចំនួន ដែលបានប្រគល់អំណាចមិនសមស្របឲ្យក្រសួងយុត្តិធម៌ នូវកិច្ចការដែលជាការទទួលខុសត្រូវផ្សេងទៀតរបស់តុលាការ។ ខណៈដែលស្ថានភាពបច្ចុប្បន្នដែលច្បាប់ទាំងបីនេះ ទំនងជាមិនស្របទៅនឹងបទដ្ឋានអន្តរជាតិ ខ្ញុំយល់ឃើញថា ការអនុម័តច្បាប់ទាំងនេះគឺជាជំហានទីមួយ ឈានទៅធ្វើកំណែទម្រង់បន្ថែមទៀត។ ដំណើរការនៃកំណែទម្រង់ប្រព័ន្ធតុលាការ គួរតែជាដំណើរការជាបន្តនៅក្នុងប្រទេសមួយ។ ច្បាប់មានចរិតលក្ខណៈបែបនេះមានការវិវត្តន៍ជានិច្ច ច្បាប់ទាំងនេះអាចត្រូវបាន និងគួរត្រូវបានធ្វើវិសោធនកម្ម ពេលណាមានការខ្វះចន្លោះ។ ខ្ញុំសង្ឃឹមដោយស្មោះថា សមាជិកតុលាការ គួរកាត់ផ្តាច់ចំណងទាក់ទងរបស់ខ្លួនជាមួយគណបក្សនយោបាយ ព្រោះវានាំឲ្យបាត់បង់ឯករាជ្យភាពនៃតុលាការ និងនាំឲ្យគេមើលឃើញពីភាពមិនឯករាជ្យនៃស្ថាប័ននេះ ហើយថា រដ្ឋាភិបាលគួរតែផ្តល់ធនធានបន្ថែមទៀត ដែលចាំបាច់សម្រាប់ឲ្យយន្តការថ្មី ដែលនឹងត្រូវបានបង្កើតឡើងដោយច្បាប់ថ្មីទាំងនេះ អនុវត្តការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ពាក់ព័ន្ធនឹងដំណើរការនេះ ខ្ញុំកត់សំគាល់ថា បើទោះជាមានការស្នើសុំម្តងហើយម្តងទៀតពីសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងរួមទាំងពីរូបខ្ញុំផ្ទាល់ក្តីក៏រដ្ឋាភិបាលបានបាត់បង់ឱកាសពិគ្រោះយោបល់លើអត្ថបទច្បាប់ទាំងនេះ។ ការពិគ្រោះយោបល់បែបនេះ អាចបាននាំឲ្យមានភាពប្រសើរឡើងមួយចំនួននៅក្នុងការព្រាងច្បាប់ដែលគួរតែបានដោះស្រាយកង្វល់មួយចំនួនដែលបានលើកឡើងពីមុន។ ការខ្វះតម្លាភាព និងការចូលរួមក្នុងការតាក់តែងច្បាប់ទាំងបីស្តីពីប្រព័ន្ធតុលាការ នាំឲ្យមានការព្រួយបារម្ភពីការយកលំនាំតាមនេះសម្រាប់ច្បាប់ដ៏ទៃទៀតនៅថ្ងៃអនាគត។ រដ្ឋាភិបាលបានបង្ហាញពីចេតនាក្នុងការអនុម័តច្បាប់មួយចំនួន ដែលអាចមានផលប៉ះពាល់នៅថ្ងៃអនាគតដល់ការការពារសិទ្ធិមនុស្ស ដូចជា ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តី

ពីឧក្រិដ្ឋកម្មទៅលើប្រព័ន្ធបច្ចេកវិទ្យា។ អាស្រ័យហេតុនេះ ខ្ញុំជម្រុញលើកទឹកចិត្តយ៉ាងខ្លាំងដល់រដ្ឋាភិបាល ធានាឲ្យមានការផ្តល់ឱកាសឲ្យភាគីពាក់ព័ន្ធទាំងឡាយ សម្តែងមតិយោបល់របស់ខ្លួនលើសេចក្តីព្រាងច្បាប់នេះ។

**កំណែទម្រង់ការបោះឆ្នោត និងសភា**

ភាពជាប់គាំងនយោបាយ ដែលជាឧបសគ្គដល់ប្រទេសនេះ អស់រយៈពេលមួយឆ្នាំកន្លងមក នៅតែជាកង្វល់ខ្លាំងសម្រាប់ខ្ញុំជាដដែល ដោយសារតែវាមានផលប៉ះពាល់ផ្ទាល់ទៅលើការទទួលបានសិទ្ធិមនុស្សដោយមនុស្សគ្រប់រូបនៅកម្ពុជា។

ក្នុងចំណោមចំណុចទាំងឡាយ នៃការចរចារវាងគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ ខ្ញុំកត់សំគាល់ឃើញថា ទំនងជាមានចំណុចសំខាន់ៗចំនួនពីរគឺៈ (១) ការព្រមព្រៀងគ្នាលើការបែងចែកអំណាចក្នុងវិស័យមួយចំនួន និង (២) កំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងដំណើរការនៃការបោះឆ្នោតទាំងមូល។ ប៉ុន្តែ ខ្ញុំមិនទាន់បានដឹងអំពីកិច្ចពិភាក្សាគ្នាអំពីកំណែទម្រង់សំខាន់ៗនៃសភាទេ។ ទាក់ទងនឹងចំណុចទីមួយ ខ្ញុំបានផ្តល់អនុសាសន៍កាលពីពេលថ្មីៗនេះថា បទបញ្ជាផ្ទៃក្នុងរបស់សភាជាទូទៅ ជាពិសេសបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា គួរតែធ្វើការពិនិត្យកែសម្រួលឡើងវិញ ដើម្បីជម្រុញឲ្យមានការបែងចែកអំណាច និងការទទួលខុសត្រូវប្រកបដោយសមធម៌និងសមាមាត្រ នៅក្នុងសកម្មភាពការងាររបស់សភា ហើយជាពិសេសតំណែងថ្នាក់ដឹកនាំនៅក្នុងគណៈកម្មការផ្សេងៗរបស់សភា។ ការនិយាយបែបនេះ ខ្ញុំទទួលស្គាល់ថា នៅក្នុងលទ្ធិប្រជាធិបតេយ្យ គណបក្សឈ្នះឆ្នោតនឹងត្រូវគ្រប់គ្រងប្រទេស ប៉ុន្តែទន្ទឹមនេះ ក៏ត្រូវយកចិត្តទុកដាក់គិតគូរឲ្យបានត្រឹមត្រូវផងដែរ ដល់មតិយោបល់របស់គណបក្សប្រឆាំង។ ក្រៅពីសេចក្តីថ្លែងអំពីគោលការណ៍ទូទៅនេះ ដោយសារថាបញ្ហានេះបាននិងកំពុងធ្វើការដោះស្រាយដោយគណបក្សនយោបាយទាំងពីរ ខ្ញុំគិតថា គេគួរតែទុកឲ្យគណបក្សទាំងពីរ ជាអ្នកសម្រេចលើការព្រមព្រៀងបែងចែកអំណាច តាមដែលពួកគេអាចទទួលយកបាន។

ត្រង់ចំណុចទីពីរ ខ្ញុំរីករាយដោយឃើញការទទួលយកដោយគណបក្សទាំងពីរគឺ គណបក្សកាន់អំណាច និងគណបក្សប្រឆាំងនូវសនិទានកម្ម និងតម្រូវការសម្រាប់កំណែទម្រង់ការបោះឆ្នោត ដូចបានបញ្ជាក់អំពីប្រធានបទនេះនៅក្នុងរបាយការណ៍របស់ខ្ញុំ។ ខ្ញុំស្វាគមន៍ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល លើកយកមកគិតគូរពីការទាមទារមួយចំនួនដែលមានជាយូរមកហើយឲ្យមានការធ្វើកំណែទម្រង់។ ខ្ញុំមានសេចក្តីរីករាយ ដោយអនុសាសន៍ដែលខ្ញុំបានផ្តល់ស្តីពីកំណែទម្រង់ការបោះឆ្នោត ឥឡូវនេះបានក្លាយជាផ្នែកមួយនៃរបៀបវារៈថ្នាក់ជាតិ រួមទាំងការផ្តល់ឋានៈធម្មនុញ្ញឯករាជ្យដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ហើយថាការចរចារនយោបាយបាននិងកំពុងបន្តធ្វើក្នុងបញ្ហានេះ។ ខ្ញុំសង្ឃឹមថា គណបក្សទាំងពីរនឹងឈានដល់ការសម្រេចមួយត្រឹមត្រូវពិតប្រាកដ

លើគោលការណ៍គ្រឹះ ជាជាងការគ្រាន់តែជាកាលានុវត្តន៍នយោបាយមួយដែលមានចរិតលក្ខណៈជាបណ្ដោះអាសន្ន។ នេះគឺជាឱកាសក្នុងការធ្វើកំណែទម្រង់មួយដ៏ទូលំទូលាយដែលមានលក្ខណៈយូរអង្វែង ស្របតាមបទដ្ឋានអន្តរជាតិ ដើម្បីឲ្យស្ថានភាពដែលបានជួបប្រទះក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកាលពីខែកក្កដា ឆ្នាំ២០១៣ នឹងមិនកើតមានជាថ្មីម្ដងទៀត។ ខ្ញុំនៅតែសង្ឃឹមថា ការពិភាក្សាអំពីការជ្រើសរើសសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) នឹងប្រព្រឹត្តទៅប្រកបដោយតម្លាភាព និងដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់។

ទន្ទឹមគ្នានេះដែរ កំណែទម្រង់ការបោះឆ្នោត មិនគួរកម្រិតកំណត់ត្រឹមតែការតែងតាំងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ឬឋានៈធម្មនុញ្ញរបស់ស្ថាប័ននេះប៉ុណ្ណោះទេ។ ខ្ញុំគាំទ្រយ៉ាងមុតមាំដល់ការបង្កើតប្រព័ន្ធច្បាស់លាស់ថ្មីមួយ នៃការចុះឈ្មោះអ្នកបោះឆ្នោត ដែលសំខាន់សម្រាប់ការប្រើប្រាស់សិទ្ធិបោះឆ្នោត។ យន្តការមួយដែលអព្យាក្រិត និងមានតម្លាភាពជាងនេះ ដើម្បីដោះស្រាយបណ្ដឹងទាក់ទងនឹងការបោះឆ្នោតនឹងបង្កើនការជឿជាក់លើដំណើរការបោះឆ្នោត។ កំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គួររួមបញ្ចូលផងដែរនូវការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធ តួនាទី និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)។ តម្លៃនៃការអនុវត្តបែបនេះ នឹងត្រូវពឹងផ្អែកមួយផ្នែក ទៅលើថាតើត្រូវធ្វើរបៀបណា ហើយនៅពេលណា។ ដូច្នេះ ខ្ញុំសូមផ្ដល់ជាអនុសាសន៍ថា គ្រប់គណបក្សពាក់ព័ន្ធ គួរតែគោរពអនុវត្តតាមគម្រោងផែនការមួយជាក់លាក់ និងពេលវេលាដែលបានកំណត់។

ទន្ទឹមនឹងកត់សំគាល់ពីចរិតលក្ខណៈនៃការចរចារដែលកំពុងបន្តធ្វើរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង ខ្ញុំយល់ឃើញថា កំណែទម្រង់សភាដ៏ឆាប់រហ័ស ដូចបានរៀបរាប់នៅក្នុងរបាយការណ៍របស់ខ្ញុំ លើចំណុចនេះគឺមានសារៈសំខាន់ ដើម្បីអាចឲ្យគណបក្សប្រឆាំងដើរតួនាទីប្រកបដោយអត្ថន័យ ក្នុងនាមជាគណបក្សប្រឆាំងមួយនៅក្នុងរដ្ឋសភា។ ក្នុងស្មារតីនេះ គណបក្សកាន់អំណាច គណបក្សប្រជាជន និងរដ្ឋាភិបាលផ្ទាល់មានការទទួលខុសត្រូវធំធេងថែមទៀត ក្នុងការបង្ហាញភាពបត់បែនជាអតិបរមា ភាពជាអ្នកដឹកនាំ និងភាពប្រកដប្រជា និងដោះស្រាយរាល់ការទាមទារឲ្យមានកំណែទម្រង់ ដើម្បីធានាការប្រព្រឹត្តទៅដោយរលូន នៃលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេស។

គណបក្សប្រឆាំង គណបក្សសង្គ្រោះជាតិ ក៏ដូច្នោះដែរ ត្រូវតែមានភាពសមហេតុផល និងភាពប្រាកដនិយម អំពីវិធីសាស្ត្ររបស់ខ្លួនក្នុងការចរចារ និងបង្កើនភាពអត់ធ្មត់ និងទំនាក់ទំនងខាងជាតិសាសន៍ដោយសុខដម្យនៅក្នុងសង្គមមួយដែលមានលក្ខណៈស្មុគ្រស្មាញដូចជាសង្គមកម្ពុជា។ ខ្ញុំបានគូសបញ្ជាក់នៅក្នុងពេល

នៃជំនួបប្រជុំរបស់ខ្ញុំជាមួយមេដឹកនាំគណបក្សសង្គ្រោះជាតិ អំពីតម្រូវការនិងអត្ថប្រយោជន៍នៃការចូលរួមរបស់ពួកគេនៅក្នុងរដ្ឋសភា ដើម្បីវឌ្ឍនភាពខ្លាំងឡើងថែមទៀត នៃប្រទេសនេះ។

សភាមួយដែលដំណើរការល្អ អាចផ្តល់សំឡេងដល់ពហុភាពនៃការទាមទារនៅក្នុងសង្គម ហើយអាចដាក់អង្គនិតិប្រតិបត្តិឲ្យទទួលខុសត្រូវ គឺតំណាងឲ្យលទ្ធិប្រជាធិបតេយ្យដែលដំណើរការល្អ។ ដើម្បីឲ្យដំណើរការនេះមានទៅបាន សមាជិកសភា ត្រូវតែអាចទៅជួបម្ចាស់ឆ្នោតតាមមណ្ឌលរបស់ខ្លួន និងអាចជួយលើកស្ទួយដល់ផលប្រយោជន៍របស់ពួកគេ។ សមាជិកសភា ត្រូវតែអាចបំពេញតួនាទីរបស់ខ្លួន មិនត្រឹមតែ ក្នុងនាមជាសមាជិកគណបក្សមួយនោះទេ ប៉ុន្តែថែមទាំង ក្នុងនាមជាបុគ្គលផងដែរ។ គណៈកម្មការនានារបស់សភា ត្រូវតែបំពេញតួនាទីរបស់ខ្លួន ក្នុងការត្រួតពិនិត្យលើភាពស្របគ្នានៃច្បាប់ជាតិទៅនឹងបទដ្ឋានអន្តរជាតិ និងពិនិត្យជាទៀងទាត់នូវបទបញ្ញា និងការអនុវត្តរបស់រដ្ឋាភិបាល ធៀបនឹងវិសាលភាពនៃច្បាប់ដើម ដែលបទបញ្ញានោះសំដៅពង្រឹងអនុវត្តច្បាប់នោះឲ្យមានប្រសិទ្ធភាព។ លទ្ធិប្រជាធិបតេយ្យ អាចដំណើរការល្អនៅកម្ពុជា ប្រសិនជាជនគ្រប់រូបគោរពបានត្រឹមត្រូវចំពោះសិទ្ធិរបស់អ្នកដទៃ នៅពេលធ្វើការទាមទារ និងការប្រើប្រាស់សិទ្ធិផ្ទាល់ខ្លួន។

## កំណែទម្រង់ក្រុមប្រឹក្សាធម្មនុញ្ញ

នៅពេលធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញ ក្នុងគោលដៅដាក់បញ្ចូលកំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ខ្ញុំលើកទឹកចិត្តផងដែរ ដល់គណបក្សនយោបាយនានា ឲ្យប្រើប្រាស់ឱកាសនេះ ដើម្បីពិចារណាអំពីការធ្វើកំណែទម្រង់ក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីឲ្យស្ថាប័ននេះឯករាជ្យពិតប្រាកដ និងមិនប្រកាន់គណបក្សនយោបាយ ក្រៅតែពីការប្រកាន់គណបក្សទាំងអស់ ឬគណបក្សពីរ។ វាមានសារៈសំខាន់សម្រាប់ស្ថាប័ននេះក្នុងការពង្រឹងការជឿជាក់ និងការគោរពពីប្រជាជនទាំងមូល នៅក្នុងភារកិច្ចដ៏សំខាន់សម្រាប់ប្រទេសជាតិ ដូចជាការដោះស្រាយវិវាទទាក់ទងនឹងការបោះឆ្នោត និងការបកស្រាយរដ្ឋធម្មនុញ្ញ រួមទាំងឋានៈសិទ្ធិមនុស្សនៅក្នុងស្ថាបត្យកម្មរដ្ឋធម្មនុញ្ញកម្ពុជា។

## សិទ្ធិដីធ្លី

នៅក្នុងដំណើរបេសកកម្មរបស់ខ្ញុំលើកនេះ ខ្ញុំបានមានជំនួបប្រជុំប្រកបដោយផ្លែផ្កាជាមួយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ខ្ញុំស្វាគមន៍អស់ពីដួងចិត្ត ចំពោះវឌ្ឍនភាពដែលរដ្ឋាភិបាល បានធ្វើក្នុងការបង្កើតឲ្យមានគោលនយោបាយសិទ្ធិដីធ្លី រួមទាំងការអនុម័តគោលនយោបាយជាតិស្តីពីលំនៅដ្ឋាន សៀវភៅសស្តីពីគោលនយោបាយដីធ្លី និងការព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ គំនិតផ្តួចផ្តើមដែលបានរង់ចាំជាយូរមកហើយនេះ បើសិនជាមានការអនុវត្តត្រឹមត្រូវនោះ វានឹងឈានទៅដោះស្រាយបណ្តឹង

ភាគច្រើន ដែលខ្ញុំបានទទួលពីបុគ្គល និងសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែមានកង្វល់អំពីបញ្ហាតម្លាភាព និងគណនេយ្យភាព និងអវត្តមាននៃយន្តការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព ទាក់ទងនឹងបទបញ្ជាលេខ០០១ របស់រដ្ឋាភិបាល និងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីទូទៅ។ ខ្ញុំមានកង្វល់ជាខ្លាំងអំពីរបាយការណ៍ពីការបណ្តេញចេញដោយហិង្សាជាច្រើន ដែលកើតមានក្នុងឆ្នាំ២០១៤ ក្នុងនោះមានទាំងការបំពារបំពានលើរូបកាយ ការដុត និងបំផ្លិចបំផ្លាញផ្ទះសម្បែង។ ពួកគេបានបង្ហាញពីតម្រូវការជាបន្ទាន់ឲ្យមាននូវគោលនយោបាយជាតិស្តីពីការតាំងទីលំនៅ ដែលកំណត់ដោយសមស្របពីដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី និងការពិនិត្យឡើងវិញ លើរបៀបដែលរដ្ឋាភិបាលដោះស្រាយបញ្ហា ទំនាស់ដីធ្លីពាក់ព័ន្ធនឹងគ្រួសារក្រីក្ររស់នៅលើដីរដ្ឋ រាប់ទាំងអ្នកដែលមិនអាចបង្ហាញភស្តុតាងជាឯកសារនៃការអះអាងរបស់ពួកគេ។ មានករណីទំនាស់ដីធ្លីរ៉ាំរ៉ៃជាច្រើនដែលមិនទាន់បានដោះស្រាយនៅឡើយ ក្នុងនោះរួមមានទំនាស់ដីធ្លីនៅតំបន់បឹងកក់ និងបុរីកីឡា នៅរាជធានីភ្នំពេញ ស្រែអំបិល និងបុទុមសាគរ ក្នុងខេត្តកោះកុង ស្ពានឆេះ ក្នុងខេត្តព្រះសីហនុ នៅទ្រមូង ក្នុងខេត្តត្បូងឃ្មុំ នៅខ្សឹម ក្នុងខេត្តក្រចេះ នៅឡពាង ក្នុងខេត្តកំពង់ឆ្នាំង និងនៅស្ទឹងកាច់ ក្នុងខេត្តប៉ៃលិន ដែលតំណាងប្រជាពលរដ្ឋបានដាក់ញត្តិមកខ្ញុំ ក្នុងអំឡុងពេលនៃដំណើរបេសកកម្មលើកនេះ។

ខ្ញុំស្វាគមន៍ដំណឹងថា ការផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីនឹងបន្តអនុវត្តមកដល់ពេលនេះ។ ការផ្អាកនេះគួរតែបន្តធ្វើរហូតដល់គោលនយោបាយរឹងមាំមួយ ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយផលប៉ះពាល់នៃសម្បទានទាំងនេះទៅលើសិទ្ធិមនុស្ស ត្រូវបានអនុវត្តត្រឹមត្រូវ។ ជំនួបពិភាក្សាមួយចំនួន ដែលខ្ញុំបានមានជាមួយសហគមន៍ ដែលរងផលប៉ះពាល់ដោយសម្បទានដី នាំឲ្យខ្ញុំយល់ឃើញថា ការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច មិនត្រូវបានអនុវត្តល្អទេនៅប្រទេសនេះ ដែលជាលទ្ធផល ធ្វើឲ្យប្រជាជនសាមញ្ញជាច្រើនជំនាន់ត្រូវរងការឈឺចាប់ដែលមិនចាំបាច់។ សូម្បីតែមេដឹកនាំជំនាន់នេះ ក៏នឹងបានបន្តធ្វើបែបនេះដែរ ផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដ៏ទៃទៀត នឹងបន្តធ្វើឲ្យមានភាពជូចត់។ ខ្ញុំមិនទាន់ឃើញមានការសិក្សាណាមួយមានលក្ខណៈទូលំទូលាយ និងអាចជឿទុកចិត្តបាននៅឡើយទេ ដែលបង្ហាញថា ប្រជាជននៃប្រទេសនេះបានទទួលចំណែកភាគផលពីសម្បទានដីសេដ្ឋកិច្ចនោះ។ របួសនិងការតស៊ូស្វិតស្វាញស្វែងរកយុត្តិធម៌របស់ប្រជាពលរដ្ឋសាមញ្ញ ដែលរងផលប៉ះពាល់ដោយការដណ្តើមយកដីធ្លី នឹងត្រូវបានគេនិយាយ ហើយនិងត្រូវបានគេនិយាយឡើងវិញ។ អំពើអយុត្តិធម៌ នឹងត្រូវគេនិយាយតៗគ្នា រហូតដល់មនុស្សជំនាន់ថ្មីសម្រាប់រយៈពេលដ៏យូរទៅមុខទៀត ប្រសិនជាបញ្ហាទាំងនោះ មិនត្រូវបានដោះស្រាយជាបន្ទាន់ទេនោះ នេះមិនត្រឹមតែករណីថ្មីប៉ុណ្ណោះទេ ប៉ុន្តែចំពោះករណីទាំងឡាយដែលប្រជាពលរដ្ឋបានរងគ្រោះដោយការបណ្តេញដោយបង្ខំជាយូរមកហើយផងដែរ។

## សិទ្ធិការងារ

ក្នុងបេសកកម្មលើនេះ ខ្ញុំបានជួបប្រាស្រ័យជាមួយអ្នកពាក់ព័ន្ធជាច្រើន ដែលធ្វើការក្នុងវិស័យទាក់ទងនឹងឧស្សាហកម្ម ដែលជាប្រភពមួយនៃការខ្វែងគំនិតគ្នា ការប្រឈមមុខដាក់គ្នា និងអំពើហិង្សាកាលពីពេលកន្លងទៅថ្មីៗនេះ។ ជំនួបប្រជុំរបស់ខ្ញុំ ជាមួយរដ្ឋមន្ត្រីក្រសួងការងារ តំណាងសហជីពកម្មករ អ្នកបញ្ញាទិញ ក៏ដូចជាតំណាងអ្នកគ្រប់គ្រង ឬម្ចាស់រោងចក្រ មានជាអាទិ៍ សមាគមកាត់ដេរ(GMAC) និងសមាគមពាណិជ្ជកម្ម (CAMFEBA) ទទួលបានលទ្ធផលល្អ។ ខ្ញុំមានសេចក្តីរីករាយដោយកត់សំគាល់ឃើញ មានមតិយល់ស្របគ្នាទូទៅមួយកើតមានក្នុងចំណោមតួអង្គសំខាន់ៗទាំងអស់ក្នុងវិស័យឧហ្សាហកម្មនេះ អំពីនិតិវិធី និងលក្ខណៈវិនិច្ឆ័យដែលត្រូវអនុវត្តក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា។ ក្នុងនាមជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋាភិបាលកម្ពុជា ត្រូវធ្វើការធានាថាប្រាក់ឈ្នួលអប្បបរមានៅថ្នាក់ជាតិ ត្រូវបានកំណត់ក្នុងកម្រិតមួយដែលគ្រប់គ្រាន់អាចឲ្យកម្មករ កម្មការិនី និងក្រុមគ្រួសាររបស់ពួកគេ រស់ក្នុងកម្រិតជីវភាពមួយសមរម្យ។

នៅក្នុងការជួបប្រាស្រ័យរបស់ខ្ញុំជាមួយអ្នកពាក់ព័ន្ធផ្សេងៗអំពីបញ្ហាការងារ ខ្ញុំមានកង្វល់ដោយឮថាកម្មករ កម្មការិនី និងអ្នកដឹកនាំសហជីពកម្មករមួយចំនួន បានប្រឈមមុខនឹងការគំរាមកំហែង និងសកម្មភាពបំភិតបំភ័យ ដោយសារតែពួកគេចូលរួមក្នុងសកម្មភាពឧស្សាហកម្ម។ ត្រង់ចំណុចនេះ ខ្ញុំមានការភ្ញាក់ផ្អើលពីការកើនឡើងខ្លាំងនៃសកម្មភាពបំភិតបំភ័យពីស្ថាប័នតុលាការទៅលើសកម្មជនសហជីពកម្មករក្នុងខែមេសា និងខែឧសភា ដែលរួមមានការចាប់ខ្លួននៅខេត្តកណ្តាល កំពង់ស្ពឺ និង តាកែវ ព្រមទាំងការតម្រូវឲ្យបង់ប្រាក់ធានានៅក្រៅឃុំជាបណ្តោះអាសន្ន ដែលមិនធ្លាប់មានពីមុនមក ចំនួន ២៥០០០ ដុល្លារ ក្នុងរឿងក្តីប្រឆាំងនឹងលោក អាត់ ធន់ ប្រធានសហជីពឯករាជ្យធំជាងគេបំផុតនៅប្រទេសកម្ពុជា ដែលត្រូវបានចោទប្រកាន់ពីបទញុះញង់។ លើសពីនេះទៀត ទន្ទឹមនឹងខ្ញុំមានការរីករាយដោយមើលឃើញការដោះលែងមនុស្សទាំង ២៥ នាក់ ដែលបានចាប់ខ្លួន និងបានកាត់ទោសពីបទជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ និងថ្ងៃទី២ ទី៣ ខែមករា ឆ្នាំ ២០១៤ ខ្ញុំមានកង្វល់ជាខ្លាំង អំពីការផ្តន្ទាទោសអ្នកទាំងនេះ ដោយគ្មានភស្តុតាងរឹងមាំគ្រប់គ្រាន់ អាចជឿទុកចិត្តបានបន្ទាប់ពីសវនាការកាត់ទោស ដែលបើតាមអ្នកសង្កេតការណ៍ឯករាជ្យជាច្រើន បញ្ជាក់ថាមិនបានបំពេញតាមបទដ្ឋានអន្តរជាតិស្តីពីការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ហើយក្នុងរឿងក្តីភាគច្រើន ត្រូវបានសម្រេចប្រឆាំងនឹងបុគ្គលទាំងឡាយ ដែលមិនបានធ្វើអ្វីក្រៅតែពីការអនុវត្តសិទ្ធិសេរីភាពជាមូលដ្ឋានរបស់គេ ក្នុងការបញ្ចេញមតិ និងការជួបប្រជុំ។ ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត ឲ្យចាត់វិធានការចាំបាច់ទាំងអស់ដើម្បីធានាថា សិទ្ធិសហជីពរបស់កម្មករ កម្មការិនីទាំងអស់ ក្នុងប្រទេសកម្ពុជា ត្រូវបានគោរពទាំងស្រុង ហើយថា

មេដឹកនាំសហជីព អាចបំពេញការងាររបស់គេក្នុងបរិយាកាសមួយដែលគ្មានការបំភិតបំភ័យ និងហានិភ័យចំពោះសន្តិសុខផ្ទាល់ខ្លួនគេ។ ត្រង់ចំណុចនេះ ខ្ញុំអំពាវនាវដល់រដ្ឋាភិបាល សូមធ្វើឲ្យប្រាកដថា ច្បាប់ណាមួយ ស្តីពីសហជីពដែលបានអនុម័ត ត្រូវលើកកម្ពស់សិទ្ធិសេរីភាពខាងសមាគមរបស់កម្មករ កម្មការិនី ជាជាងការដាក់ការរឹតត្បិតលើពួកគេ។ ខ្ញុំមានសេចក្តីរីករាយ ដោយសារថា រដ្ឋាភិបាលបន្តដំណើរការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់នេះ និងដោយមានឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង ធានាចំពោះខ្ញុំថា ច្បាប់នេះនឹងអនុលោមទាំងស្រុងតាមអនុសញ្ញាអង្គការពលកម្មអន្តរជាតិ(ILO) និងរដ្ឋធម្មនុញ្ញកម្ពុជា។ ខ្ញុំយល់ឃើញថា វាចាំបាច់ក្នុងការសើរើពិនិត្យឡើងវិញជាដំកំភួន លើសេចក្តីព្រាងច្បាប់បច្ចុប្បន្ន ដើម្បីធានាអនុលោមភាពនៃច្បាប់នេះ។ ខ្ញុំសង្កត់ធ្ងន់ពីសារៈសំខាន់នៃការពិគ្រោះយោបល់ដែលមានការចូលរួម និងប្រកបដោយអត្ថន័យលើសេចក្តីព្រាងច្បាប់នេះ។

## លំហលិទ្ធិប្រជាធិបតេយ្យ

ខ្ញុំមានការព្រួយបារម្ភ ដោយឃើញថា លំហលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា បានរួមតូច ចាប់តាំងពីដំណើរទស្សនកិច្ចចុងក្រោយរបស់ខ្ញុំក្នុងខែមករា ឆ្នាំនេះ។ ការហ៊ុំព័ទ្ធទីលានប្រជាធិបតេយ្យដោយបន្លារលួស មិនមានហេតុផលផ្លូវច្បាប់ទេ ហើយវាមានផលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាពជាមូលដ្ឋាន ក្នុងការបញ្ចេញមតិ និងការជួបជុំរបស់ប្រជាជនកម្ពុជាទាំងអស់។ នៅពេលបញ្ចប់ដំណើរទស្សនកិច្ចនេះ ខ្ញុំនៅមិនទាន់ដឹងច្បាស់អំពីការនៅមានអត្ថិភាព ឬអត់នោះទេ ពីបំរាមធ្វើបាតុកម្ម ហើយខ្ញុំអំពាវនាវដល់រដ្ឋាភិបាលឲ្យប្រកាសជាសាធារណៈថា បំរាមដែលរដ្ឋាភិបាលបានដាក់កាលពីដើមខែមករា ដែលមិនមានមូលផលផ្លូវច្បាប់តាំងតែពីដើមដំបូងនោះគឺមិនមានទៀតឡើយ។ ម្យ៉ាងវិញទៀត ខ្ញុំអំពាវនាវដល់រដ្ឋាភិបាល ឲ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការស៊ើបអង្កេតលើព្រឹត្តិការណ៍ហិង្សានៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ និងនៅថ្ងៃទី៣ ខែ មករា ឆ្នាំ២០១៤ ដែលបណ្តាលឲ្យស្លាប់មនុស្សប្រាំពីរនាក់ ច្រើននាក់ទៀតរងរបួស និងបាត់ខ្លួនអនីតិជនម្នាក់។ ចំពោះចំណុចចុងក្រោយនេះ ខ្ញុំអំពាវនាវឲ្យរដ្ឋាភិបាលបញ្ជាក់ប្រាប់ពីវិធានការដែលបានចាត់ឡើង ដើម្បីការស៊ើបអង្កេតលើករណីនៃការបាត់ខ្លួនកុមារនេះ ដែលមានគេឃើញកុមារនោះចុងក្រោយថា បានរងរបួស និងមានឈាមហូរដោយសារត្រូវគ្រាប់ត្រង់ដើមទ្រូង នៅលើផ្លូវវែងស្រែងនៅថ្ងៃទី៣ ខែមករា។

ក្រៅពីនេះ ខ្ញុំកត់សំគាល់អំពីគម្រោងធ្វើច្បាប់ ដែលអាចប៉ះពាល់លំហប្រជាធិបតេយ្យនៅកម្ពុជា។ តំណាងសង្គមស៊ីវិល បានបង្ហាញពីកង្វល់របស់ខ្លួនចំពោះសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិត និងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ច្បាប់ណាមួយ ដែលចែងពីសេរីភាពក្នុងការបញ្ចេញមតិតាមប្រព័ន្ធអេឡិចត្រូនិក និងការបង្កើត និងប្រតិបត្តិការរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវតែជាកង្វល់ផ្ទាល់សម្រាប់សង្គមស៊ីវិល។ កង្វល់ទាំងនេះ រិតតែធ្ងន់ធ្ងរថែមទៀតដោយសារការខកខានរបស់

រដ្ឋាភិបាល ក្នុងការផ្តល់ព័ត៌មានអំពីខ្លឹមសារ និងស្ថានភាពនៃសេចក្តីព្រាងច្បាប់ទាំងនេះ និងពេលវេលាដែលត្រូវប្រើសម្រាប់អនុម័តច្បាប់នេះ។ ភាពលាក់លៀមក្នុងសង្គមមួយដែលប្រេះឆា បណ្តុះនូវការមន្ទិលសង្ស័យ។ ខ្ញុំបានយកឱកាសនេះពិភាក្សាជាមួយរដ្ឋាភិបាល លើសេចក្តីព្រាងច្បាប់ទាំងពីរនេះ។ ខ្ញុំសូមបញ្ជាក់ពីសិទ្ធិរបស់សាធារណជន រាប់ទាំង សមាជិកសង្គមស៊ីវិល ចូលរួមក្នុងដំណើរការតាក់តែងច្បាប់។

## ស្ថាប័នជាតិសិទ្ធិមនុស្សឯករាជ្យ

វិធីសាស្ត្រដែលខ្ញុំកំណត់សម្រាប់ការបំពេញអាណត្តិរបស់ខ្ញុំ ដំបូងបង្អស់គឺការវាយតម្លៃអំពីប្រសិទ្ធភាពរបស់ស្ថាប័នរដ្ឋនានា ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅកម្ពុជា។ ស្ថាប័នតុលាការជាចំណុចផ្តោតនៃរបាយការណ៍សំខាន់បឋមរបស់ខ្ញុំ។ នៅក្នុងលទ្ធិប្រជាធិបតេយ្យមួយដែលដំណើរការល្អ ប្រសិនជាប្រជាពលរដ្ឋកើតទុកមិនសុខចិត្តក្នុងរឿងអ្វីមួយ ពួកគេអាចដាក់បណ្តឹងទៅតុលាការ។ ទោះជាយ៉ាងណាក៏ដោយ ផ្អែកលើព័ត៌មានដែលខ្ញុំបានទទួល ស្ថាប័នតុលាការ មិនទំនងជាទទួលបានការគោរព ឬការជឿជាក់ពីប្រជាជនច្រើនទេ។ សម្រាប់ប្រជាជនសាមញ្ញភាគច្រើន ថ្លៃទទួលបានសេវាពីតុលាការក៏មានតម្លៃខ្ពស់ហួសពេក។ ក្រុមជនដែលគេមិនសូវគិតគូរភាគច្រើន បានប្រាប់ខ្ញុំផងដែរ ពីការដែលពួកគេត្រូវបានរើសអើងពីស្ថាប័ន ដែលគួរតែការពារ និងលើកកំពស់សិទ្ធិរបស់គេ។ បន្ទាប់ពីពិនិត្យលើស្ថាប័នតុលាការ ខ្ញុំងាកមកពិនិត្យលើប្រសិទ្ធភាពនៃស្ថាប័នសភា និងពីលទ្ធភាពរបស់សភា ក្នុងការតំណាងឲ្យម្ចាស់ឆ្នោតរបស់ខ្លួន។ ការរកឃើញរបស់ខ្ញុំ បង្ហាញថាមានទំនាក់ទំនងផ្ទាល់តិចតួចរវាងសមាជិកសភា និងប្រជាពលរដ្ឋ។ នៅក្នុងលទ្ធិប្រជាធិបតេយ្យដែលដំណើរការល្អ ប្រជាពលរដ្ឋអាចទៅរកតុលាការ ឬតំណាងរាស្ត្ររបស់ខ្លួន ដើម្បីប្រាប់ពីទុក្ខកង្វល់របស់ខ្លួន និងសុំឲ្យជួយធ្វើអន្តរាគមន៍។ ប៉ុន្តែ នៅប្រទេសកម្ពុជា សមាជិកសភា មិនអាចដាក់ឲ្យអំណាចនីតិប្រតិបត្តិទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនបានទេ ដោយហេតុនេះហើយ សមាជិកសភាមិនអាចតំណាងផលប្រយោជន៍ម្ចាស់ឆ្នោតរបស់ខ្លួនប្រកបដោយអត្ថន័យបានឡើយ។ អាស្រ័យហេតុនេះ ខ្ញុំបានបន្តធ្វើរបាយការណ៍ស្តីពីកំណែទម្រង់សភា ជាមួយនឹងកំណែទម្រង់ការបោះឆ្នោត។ នៅក្នុងរបាយការណ៍នីមួយៗទាំងនេះ ខ្ញុំបានបង្ហាញពីភាពខ្វះចន្លោះ ដែលមាន និងបានផ្តល់ជាអនុសាសន៍មួយចំនួន សម្រាប់កំណែទម្រង់ស្ថាប័នទាំងនេះ។

ខ្ញុំបានដឹងថា ការខកខានរបស់ស្ថាប័នរដ្ឋនានា ក្នុងការលើកកំពស់សិទ្ធិរបស់ប្រជាពលរដ្ឋ ជាហេតុដែលនៅគ្រប់ដំណើរបេសកកម្មរបស់ខ្ញុំ មានប្រជាពលរដ្ឋសាមញ្ញជាច្រើននាក់មកជួបខ្ញុំ ដោយការអស់សង្ឃឹម ដើម្បីបង្ហាញពីស្ថានភាពលំបាករបស់ពួកគេ និងដាក់ញត្តិស្នើឲ្យខ្ញុំជួយធ្វើអន្តរាគមន៍។ នេះក៏ជាមូលហេតុផងដែរ ដែលប្រជាពលរដ្ឋជាច្រើនជួបជុំគ្នា និងដាក់ញត្តិដោយផ្ទាល់នៅគេហដ្ឋានរបស់នាយករដ្ឋមន្ត្រី អង្គការសហប្រជាជាតិ និងស្ថានទូតនានា ហើយក៏ជាមូលហេតុ ដែលពួកគេដើរតាមដងផ្លូវ ដើម្បីសំដែងពីទុក្ខកង្វល់របស់ខ្លួន។

នៅក្នុងបរិបទនេះ ខ្ញុំបានគិតថា វាដល់ពេលត្រូវពិនិត្យមើលពីតម្រូវការ ឬការគួរឲ្យចង់បង្កើតស្ថាប័នជាតិសិទ្ធិមនុស្សឯករាជ្យនៅកម្ពុជា។ ខ្ញុំបានពិភាក្សាជាមួយអ្នកពាក់ព័ន្ធជាច្រើន នៅក្នុងបេសកកម្មរបស់ខ្ញុំកាលពីដើមឆ្នាំនេះ ក៏ដូចជា នៅក្នុងបេសកកម្មនេះផងដែរ អំពីលទ្ធភាពបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សឯករាជ្យ ដែលអាចពង្រីកវិសាលភាពនៃសិទ្ធិ ដើរតួនាទីជាស្ថាប័នចម្បងក្នុងការការពារសិទ្ធិប្រជាពលរដ្ឋ ធ្វើអនុសាសន៍ស្ដីពីគោលនយោបាយទៅរដ្ឋាភិបាល និងធានាការពារសិទ្ធិពលរដ្ឋ ដោយមានសិទ្ធិអំណាចស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស។ ទន្ទឹមនឹងទំនងជាមានការព្រមព្រៀងដ៏ទូលំទូលាយស្ដីពីតម្រូវការសម្រាប់យន្តការបែបនេះនៅក្នុងប្រទេសនេះ មានមជ្ឈដ្ឋានផ្សេងៗបានបង្ហាញពីកង្វល់ថា ស្ថិតក្នុងស្ថានភាពនយោបាយបច្ចុប្បន្ននេះ តើគេអាចបង្កើតគណៈកម្មការជាតិសិទ្ធិមនុស្សឯករាជ្យ និង/ឬ តែងតាំងមនុស្សឯករាជ្យពិតប្រាកដដែលមានគុណសម្បត្តិគ្រប់គ្រាន់ធ្វើជាសមាជិកគណៈកម្មការនេះបានដែរ ឬទេ។ ប្រជាពលរដ្ឋខ្លះបានប្រាប់ខ្ញុំថា " យើងមិនអាចទៅតុលាការ សភា ឬនីតិប្រតិបត្តិបានទេ។ ប្រព័ន្ធនេះខូចហើយ ប្រព័ន្ធរដ្ឋបាលសាធារណៈមិនដំណើរការទេ។ យើងពិតជាត្រូវការគណៈកម្មការមួយដូចនេះ ដើម្បីដាក់ឲ្យស្ថាប័នសាធារណៈទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។ ប៉ុន្តែមានបញ្ហាអំពើពុករលួយ ភាពមិនឯករាជ្យនៃស្ថាប័ន ស្ថាប័នថ្មីមួយដែលនឹងបង្កើតឡើង ក៏នឹងមានដូចគ្នាទៅនឹងស្ថាប័នដទៃទៀត ដែលយើងមានដែរ"។ នេះជាមតិដែលបានសំដែងឡើងដោយដៃគូសន្ទនាភាគច្រើនរបស់ខ្ញុំ។ របៀបដែលសេចក្ដីព្រាងច្បាប់មួយចំនួន នៅពេលថ្មីៗនេះ ត្រូវបានបញ្ជូនយ៉ាងប្រញាប់ប្រញាលទៅសភាដោយគ្មានការពិភាក្សា ឬពិគ្រោះយោបល់ពិតប្រាកដ បានបន្ថែមការសង្ស័យដល់តំណាងសង្គមស៊ីវិលមួយចំនួន។

ទន្ទឹមនឹងការគិតគូរត្រឹមត្រូវពីទស្សនៈបែបនេះ ខ្ញុំយល់ឃើញថា ប្រសិនជាភាគីទាំងអស់ប្ដេជ្ញាធ្វើឲ្យជោគជ័យ ការងារអាចចាប់ផ្ដើមឈានទៅបង្កើតស្ថាប័នមួយនេះ។ ក្នុងប្រទេសជាច្រើន ដោយមានស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យពេញសិទ្ធិ លក្ខខណ្ឌសម្រាប់ការបង្កើតដំបូង មិនសឹងតែល្អពីដំបូងនោះទេ ប៉ុន្តែគេបានមើលឃើញពីការរីកចម្រើនក្នុងពេលត្រឹមត្រូវ។ ដោយពិចារណាទៅលើកេរ្តិ៍ដំណែលនៃសោកនាដកម្មក្នុងអតីតកាល និងជាពិសេសកម្រិតនៃផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច ទៅលើអ្នកក្រីក្របំផុត និងសហមន៍ជនជាតិដើមភាគតិច និងកម្រិតនៃបញ្ហាប្រឈមខាងសិទ្ធិមនុស្សដែលប្រទេសនេះកំពុងជួបប្រទះ ខ្ញុំជឿជាក់ពីតម្រូវការឲ្យមានគណៈកម្មការជាតិសិទ្ធិមនុស្សមួយដែលឯករាជ្យពិតប្រាកដនៅកម្ពុជា។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា វានឹងនាំមកនូវតម្លៃបន្ថែមដល់ហេដ្ឋារចនាសម្ព័ន្ធសិទ្ធិមនុស្សបច្ចុប្បន្ន ដរាបណាតែឯករាជ្យភាពរបស់គណៈកម្មការនេះ ត្រូវបានធានាពេញលេញ ទាំងក្នុងច្បាប់ ទាំងក្នុងការអនុវត្តជាក់ស្ដែង ដោយអនុលោមទាំងស្រុងទៅនឹងគោលការណ៍ទីក្រុងប៉ារីស។

## ស្ថានភាពពលករធ្វើមាតុភូមិនិវត្តពីប្រទេសថៃឡង់ដ៍

ការធ្វើមាតុភូមិនិវត្តរបស់ពលករកម្ពុជា និងគ្រួសាររបស់ពួកគេ ជាង ២២៥០០០ នាក់ មកពីប្រទេសថៃឡង់ដ៍ ដែលក្នុងនោះមានស្ត្រីជាង ៧៥០០០ នាក់ និងកុមារជាង ១៥០០០ នាក់ ក្នុងអំឡុងពេលមិនដល់ពីរសប្តាហ៍ផង និងរបាយការណ៍ពីការស្លាប់មនុស្សច្រើននាក់នៅក្នុងដំណើរការនេះ គឺជាកង្វល់ខាងសិទ្ធិមនុស្ស។ ខ្ញុំបានពិភាក្សាបញ្ហានេះជាច្រើនដង នៅក្នុងដំណើរបេសកកម្មរបស់ខ្ញុំ ក្នុងជំនួបប្រជុំជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអ្នកដទៃទៀត។ ខ្ញុំសរសើរពីកិច្ចខិតខំប្រឹងប្រែងភ្លាមៗរបស់រដ្ឋាភិបាលកម្ពុជា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការដឹកជញ្ជូនពលករពីតំបន់ព្រំដែនវិលត្រឡប់ទៅកាន់សហគមន៍របស់ពួកគេវិញ និងជួយអ្នកធ្វើមាតុភូមិនិវត្តក្នុងដំណើរការធ្វើសមាហរណកម្ម ជាពិសេស ដោយពិចារណាពីភាពធំសម្បើមនៃបញ្ហាប្រឈម ដែលបណ្តាលមកពីការវិលត្រឡប់ភ្លាមៗនិងច្រើនសន្ធឹកសន្ធាប់នេះ។ ទោះជាអាណត្តិរបស់ខ្ញុំ ត្រូវពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាក្តីក៏ ខ្ញុំបានទទួលព័ត៌មានពីរដ្ឋាភិបាលថៃឡង់ដ៍ស្តីពីជំហររបស់ខ្លួនលើបញ្ហានេះ។ ខ្ញុំយល់ឃើញថា រដ្ឋាភិបាលថៃឡង់ដ៍ គួរតែស៊ើបអង្កេតករណីដែលបានរាយការណ៍ពីការស្លាប់ប្រជាជនកម្ពុជានៅប្រទេសថៃឡង់ដ៍ ហើយត្រូវបញ្ជាក់ឲ្យច្បាស់ពីមូលហេតុ នៅពីខាងក្រោយការបញ្ជូនពលករខ្មែរយ៉ាងច្រើនសន្ធឹកសន្ធាប់ឲ្យវិលត្រឡប់មកវិញភ្លាមៗបែបនេះ។ ខ្ញុំឆ្លៀតឱកាសនេះអំពាវនាវដល់រដ្ឋាភិបាលថៃឡង់ដ៍ឲ្យស៊ើបអង្កេតដូចគ្នាដែរ នូវករណីនៃការស្លាប់អ្នកកាប់ឈើជនជាតិខ្មែរ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដែលជាក្តីកង្វល់របស់ខ្ញុំរហូតមក។

ដោយសារប្រាក់ផ្ញើមកពីពលករ ជាប្រភពចំណូលមួយដ៏សំខាន់សម្រាប់សហគមន៍ជនបទជាច្រើននៅកម្ពុជា ខ្ញុំមានការរីករាយដែលថា រដ្ឋាភិបាលនៃប្រទេសទាំងពីរ មានឆន្ទៈសម្របសម្រួលតាមផ្លូវច្បាប់ចំពោះការវិលត្រឡប់ទៅប្រទេសថៃឡង់ដ៍វិញ ចំពោះពលករទាំងឡាយណាដែលមានបំណងធ្វើដូច្នេះ តាមរបៀបមួយដែលបង្កើនកិច្ចការពាររបស់ខ្លួនប្រឆាំងនឹងការជួញដូរមនុស្ស និងការរំលោភសិទ្ធិមនុស្សផ្សេងទៀត។ កិច្ចខិតខំរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការសម្រួលនិយតកម្មស្ថានភាពផ្លូវច្បាប់របស់ពលករ ដែលចេញទៅធ្វើការនៅក្រៅប្រទេស រាប់ទាំងការកាត់បន្ថយចំណាយក្នុងការទទួលបានលិខិតឆ្លងដែនថ្មី និងសម្របសម្រួលការចេញលិខិតឆ្លងដែនរបស់ពួកគេ គឺជារឿងគួរឲ្យសរសើរ។

## សេចក្តីសន្និដ្ឋាន

ខ្ញុំបញ្ជាក់ឡើងវិញពីការយល់ឃើញរបស់ខ្ញុំថា កំណែទម្រង់មួយពិតប្រាកដក្នុងដំណើរនៃអភិបាលកិច្ច គឺជារឿងជៀសមិនផុតក្នុងប្រទេសកម្ពុជា។ ប៉ុន្តែវាហាក់នៅមានការស្ទាក់ស្ទើរខ្លះ ហើយការខ្វះឆន្ទៈស្មោះត្រង់ក្នុង

ការទទួលស្គាល់សារដែលបានសំដែងយ៉ាងលឺខ្លាំងៗ និងច្បាស់លាស់របស់ប្រជាពលរដ្ឋ។ សិល្បៈនៃការគ្រប់គ្រងគឺជាសិល្បៈនៃការចាត់ចែងការផ្លាស់ប្តូរ។ វានិយាយពីការបង្ហាញពីភាពជាបុរសរដ្ឋ និងអាចយកអ្នកផ្សេងដើរតាមជាមួយផង។ អ្នកដែលជំទាស់នឹងការផ្លាស់ប្តូរ យល់ឃើញថា ថ្ងៃណាមួយ ការផ្លាស់ប្តូរត្រូវបានបង្ខំលើពួកគេដោយការវិវត្តហួសពីការគ្រប់គ្រងរបស់គេ។ បញ្ហានេះបានកើតឡើងនៅទូទាំងសេចក្តីរីកចម្រើនរបស់មនុស្ស។ ដោយបានសិក្សាពីសង្គមកម្ពុជា និងប្រវត្តិសាស្ត្ររបស់ប្រទេសនេះដោយប្រុងប្រយ័ត្ន ហើយបានប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ខ្ញុំយល់ឃើញថា វាជាករណីយកិច្ចរបស់ខ្ញុំត្រូវបញ្ជាក់ថា ប្រសិនជាកំណែទម្រង់ពិតប្រាកដមិនបានធ្វើឲ្យបានឆាប់ៗទេនោះ ប្រទេសនេះត្រូវប្រថុយប្រថាននឹងការវិលត្រឡប់ជាថ្មីនូវអំពើហិង្សា។ ខ្ញុំដឹងពីការខកចិត្តជាខ្លាំងមានក្នុងចំណោមប្រជាពលរដ្ឋ ជាពិសេសយុវជន អ្នកក្រីក្រនៅជនបទ និងអ្នកគ្មានសិទ្ធិបោះឆ្នោត និងបាត់បង់សិទ្ធិបោះឆ្នោតដទៃទៀត អំពីការកង្វះវឌ្ឍនភាពលើកំណែទម្រង់វិស័យមួយចំនួនដែលបានសន្យា។ ប្រសិនជាកំណែទម្រង់មិនបានធ្វើទាន់ពេល និងពិតប្រាកដទេនោះ ហើយប្រសិនជាគណបក្សមួយបន្តធ្វើការងារដូចធម្មតានៅក្នុងរដ្ឋសភា ករណីនេះអាចមានហេតុផលដែលកើតឡើងជាបន្តបន្ទាប់ រាប់ទាំង ការធ្វើមិនបានសម្រេចតាមគោលការណ៍ជាមូលដ្ឋាននៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលផ្អែកលើតម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

របាយការណ៍គ្រឹះនិងសំខាន់ចំនួនបួន ដែលខ្ញុំបានដាក់ជូនអង្គការសហប្រជាជាតិ នៅទូទាំងការងាររបស់ខ្ញុំក្នុងប្រទេសនេះ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក ត្រូវបានរៀបចំឡើងសំដៅជួយដល់រដ្ឋាភិបាល គណបក្សប្រឆាំង និងអ្នកពាក់ព័ន្ធឯទៀតនៅក្នុងសង្គមកម្ពុជា ដើម្បីចាប់យកការផ្លាស់ប្តូរ។ ខ្ញុំរីករាយចំពោះការវឌ្ឍនភាពក្នុងការអនុវត្តអនុសាសន៍មួយចំនួនរបស់ខ្ញុំ ហើយការទទួលយកដាក់ចូលក្នុងរបៀបវារៈជាតិ នូវអនុសាសន៍ទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោត និងកំណែទម្រង់សភាជាពិសេស។ ប៉ុន្តែ ខ្ញុំកត់សំគាល់ឃើញថា កំណែទម្រង់ចំណុចទីពីរនេះ នៅមិនទាន់ឃើញមានការរីកចម្រើនពិតប្រាកដទេ ទោះបីជាវាជាគន្លឹះក្នុងការដោះស្រាយភាពជាប់គាំងនយោបាយបច្ចុប្បន្ននេះក្តី។ ត្រង់ចំណុចនេះ អ្វីដែលត្រូវការចាំបាច់នោះគឺការធានាអះអាងមួយច្បាស់លាស់ថា អនុសាសន៍សម្រាប់កំណែទម្រង់ការបោះឆ្នោត នឹងត្រូវបានអនុវត្តក្នុងកំរិតនៃភាពប្រាកដប្រជា ដែលចាំបាច់ ដើម្បីទទួលបានការជឿជាក់ និងការទុកចិត្តពីប្រជាពលរដ្ឋ ដោយមានក្របខ័ណ្ឌពេលវេលាមួយដាច់ខាតដើម្បីរៀបចំ និងអនុវត្តកំណែទម្រង់នេះ រាប់ទាំងតាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។

ខ្ញុំបានចែករំលែកទស្សនៈរបស់ខ្ញុំដោយស្មោះត្រង់ជាមួយសមាជិកជាន់ខ្ពស់មួយចំនួន ក្នុងជួររដ្ឋាភិបាល ក៏ដូចជាមេដឹកនាំបក្សប្រឆាំងដែលខ្ញុំបានបញ្ជាក់ពីតម្រូវការ និងអត្ថប្រយោជន៍ពីការចូលរួមរបស់ពួកគេ ក្នុងរដ្ឋសភា។ ខ្ញុំនឹងចាកចេញទៅដោយក្តីសង្ឃឹមថា សុភវិនិច្ឆ័យនឹងកើតមាននៅថ្ងៃណាមួយនៅកម្ពុជា ហើយនឹង

នាំប្រទេសនេះឆ្ពោះទៅរកសន្តិភាពយូរអង្វែង ការអភិវឌ្ឍប្រកបដោយសមធម៌ លទ្ធិប្រជាធិបតេយ្យធំធេង នីតិរដ្ឋពិតប្រាកដ និងការគោរពសិទ្ធិមនុស្សល្អប្រសើរជាងមុន។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងនៅទីក្រុងហ្សឺណែវ ដែលបានជួយឧបត្ថម្ភគាំទ្រដល់រូបខ្ញុំ នៅក្នុងអំឡុងពេលនៃការបំពេញបេសកកម្មរបស់ខ្ញុំ។

## ចប់

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គលឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់។ បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវីអាជីពមួយរូប នៃគណៈមេធាវីមីឌីលថឹមភីល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ីនៃនីតិអន្តរជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្តីអាស៊ីនៃច្បាប់អន្តរជាតិ បោះពុម្ពផ្សាយដោយរោងពុម្ពនៃសាកលវិទ្យាល័យខេមប្រីដជ៍។*

(*) ឆែកមើលរបាយការណ៍ចុងក្រោយបំផុតរបស់អ្នករាយការណ៍ពិសេស បញ្ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប (A/HRC/24/36)៖

http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session24/Pages/ListReports.aspx

សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា៖

http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx

រាល់សំណើព័ត៌មានទាក់ទងនឹងអ្នករាយការណ៍ពិសេស អាចសរសេរមកកាន់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។ សូមទាក់ទងមក កញ្ញា ប៊ុស្រា រ៉ាម៉ាន់ តាមរយៈទូរស័ព្ទលេខ (+៨៥៥ ០១២ ៧៩០១៧៨/ អ៊ីម៉េល៖ *brahman@ohchr.org)*

សំរាប់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប ៖

សូមទាក់ទងមក សាប៉ៀ ស៊ីលាយ៉ា សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉េល xcelaya@ohchr.org)

សម្រាប់ព័ត៌មានបន្ថែមអំពីការងាររបស់អ្នករាយការណ៍ពិសេស សូមទាក់ទងមក ៖ នៅទីក្រុងហ្សឺណែវ កញ្ញា អ័លហ្គាណាកាចូ តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉េល onakajo@ohchr.org

សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង លើបណ្តាញព័ត៌មានសង្គម ៖

ហ្វេសប៊ុក៖ https://www.facebook.com/unitednationshumanrights

ទ្វីតធឺ៖ http://twitter.com/UNrightswire

ហ្គោហ្គីល៖Google+ gplus.to/unitednationshumanrights

យូធូប៖ http://www.youtube.com/UNOHCHR

បរិយាយសាច់រឿង ៖ http://storify.com/UNrightswire